# ការប្រគល់ ទទួល ឯកសារនិងប្រព័ន្ធសម្រាប់គម្រោង FMIS

ផ្អែកលើសកម្មភាពនៅដំណាក់កាលនីមួយៗក្នុងកំឡុងពេលនៃការអនុវត្តគម្រោង **FMIS** នឹងមានការប្រគល់ទទួលទិន្នផលសម្រេចជាពីរបែប ទី ១. ឯកសារ និងទី២. ប្រព័ន្ធ/ប្រព័ន្ធរង ។ ការប្រគល់ទទួលទិន្នផលសម្រេចនេះ នឹងឆ្លើយតបទៅតាមខ្សែបន្ទាត់ការងារ (**work streams**) នីមួយៗ ដែលរៀបរាប់លម្អិតដូចខាងក្រោម÷

## ខ្សែបន្ទាត់ការងារសម្រាប់ការគ្រប់គ្រងគម្រោង÷

នៅក្នុងដំណាក់កាលចាប់ផ្តើម និងស្វែងយល់ស៊ីជម្រៅ ការប្រគល់ទទួលទិន្នផលសម្រេចនៃខ្សែបន្ទាត់ការងារសម្រាប់ការគ្រប់គ្រងគម្រោងរួមមាន ផែនការគ្រប់គ្រងគម្រោង និង របាយការណ៍គម្រោង FMIS ។ ផែនការគ្រប់គ្រងគម្រោង ត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាមដំណើរការអនុវត្តគម្រោង FMIS

របាយការណ៍គម្រោង FMIS ត្រូវបានចែកចាយប្រចាំខែ សម្រាប់ផ្តល់នូវស្ថានការនៃសកម្មភាពគន្លឹះៗទាំងឡាយរបស់គម្រោង FMIS ក្នុងកំឡុងពេលធ្វើរបាយការណ៍ ការសង្ខេបពីស្ថានការនៃគោលដៅសំខាន់ៗ និងសកម្មភាពគន្លឹះសម្រាប់ការធ្វើរបាយណ៍បន្ទាប់ ។ រាល់ហានិភ័យ បញ្ហា ការត្រួតពិនិត្យការផ្លាស់ប្តូរ ការអនុលោមតាម នឹងត្រូវបានរំលេចនៅក្នុងរបាយការណ៍ប្រចាំខែ ។

ការប្រគល់ទទួលទិន្នផលសម្រេចសម្រាប់ខ្សែបន្ទាត់ការងារគ្រប់គ្រងគម្រោងនៅក្នុងដំណាក់កាលប្រើប្រាស់ប្រព័ន្ធគឺ ផែនការអនុវត្តគម្រោង (ជាផ្នែកមួយនៃ ផែនការគ្រប់គ្រងគម្រោង ដែលនឹងត្រូវបង្កើតឡើងក្នុងដំណាក់កាលប្រើប្រាស់ប្រព័ន្ធសម្រាប់ប្រើនៅពេលដាក់ប្រព័ន្ធឱ្យអនុវត្តនៅអគ្គនាយកដ្ឋានរតនាគារជាតិ និងនៅអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនៅពេលដាក់ប្រព័ន្ធឱ្យប្រើប្រាស់ជាបន្តបន្ទាប់) ។

## ខ្សែបន្ទាត់ការងារសម្រាប់នីតិវិធីអនុវត្តការងារ÷

នៅដំណាក់កាលស្វែងយល់ស៊ីជម្រៅ ការប្រគល់ទទួលទិន្នផលសម្រេចនៃខ្សែបន្ទាត់ការងារសម្រាប់នីតិវិធីអនុវត្តការងារ រួមមាន ព័ត៌មានបញ្ជាក់លម្អិត និង ការវិភាគចន្លោះខ្វះខាត ។

នៅដំណាក់កាលស្ថាបនាប្រព័ន្ធ ការប្រគល់ទទួលទិន្នផលសម្រេចនៃខ្សែបន្ទាត់ការងារនេះ រួមមាន ឯកសារ និង ប្រព័ន្ធ/ប្រព័ន្ធរង ។ ឯកសារដែលប្រគល់ទទួល មានឈ្មោះថា ឯកសាររៀបចំ និងស្ថាបនាប្រព័ន្ធ (System Design and Setup Documents) និង ប្រព័ន្ធ/ប្រព័ន្ធរង ដែលប្រគល់ទទួល មានឈ្មោះថា ការរៀបចំ និង ដំឡើងប្រព័ន្ធឱ្យស្របតាមនីតិវិធីការងារជាក់ស្តែង (System Design and Configuration)

ខ្សែបន្ទាត់ការងារសម្រាប់ការគ្រប់គ្រងការផ្លាស់ប្តូរ និង ការបណ្តុះបណ្តាល÷

ការប្រគល់ទទួលទិន្នផលសម្រេចចម្បងនៃខ្សែបន្ទាត់ការងារនេះស្ថិតនៅក្នុងដំណាក់កាលស្វែងយល់ស៊ីជម្រៅ ដែលឯកសាររួមមាន ផែនការទំនាក់ទំនងផ្សព្វផ្សាយ (សម្រាប់ការគ្រប់គ្រងការផ្លាស់ប្តូរ) និង ផែនការបណ្តុះបណ្តាល (សម្រាប់ការងារបណ្តុះបណ្តាល) ។

ខ្សែបន្ទាត់ការងារសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ÷

ខ្សែបន្ទាត់ការងារនេះនឹងត្រូវបានប្រគល់ទទួលទិន្នផលសម្រេចនៅក្នុងដំណាក់កាលនីមួយៗ ហើយនៅដំណាក់កាលមួយចំនួន ការប្រគល់ទទួលរួមមាន ឯកសារ និង ប្រព័ន្ធ/ប្រព័ន្ធរង។

ក្នុងដំណាក់កាលស្វែងយល់ស៊ីជម្រៅ នឹងមានការប្រគល់ទទួលនូវ ប្រព័ន្ធ/ប្រព័ន្ធរង ដែលមានឈ្មោះថា មជ្ឈដ្ឋានអភិវឌ្ឍន៍/សាកល្បង និង ការបណ្តុះបណ្តាល ។

ការប្រគល់ទទួលទិន្នផលសម្រេចនៅក្នុងដំណាក់កាលស្ថាបនា គឺជាឯកសាររៀបចំស្ថាបត្យកម្មបច្ចេកទេស (Technical Architecture Design) រួមមាន ស្ថាបត្យកម្ម LAN/WAN និង មជ្ឈមណ្ឌលទិន្នន័យ និង LAN/WAN នៅថ្នាក់កណ្តាល និង រួមទាំងកម្មវិធីកុំព្យូទ័រសម្រាប់អ៊ីមែលផងដែរ។

LAN/WAN នៅគ្រប់រតនាគារខេត្ត មជ្ឈមណ្ឌលសង្គ្រោះទិន្នន័យ មជ្ឈមណ្ឌលទិន្នន័យ និង មជ្ឈដ្ឋានប្រើប្រាស់ប្រព័ន្ធ ដែលនឹងត្រូវបានរៀបចំរួចរាល់ គឺជាការប្រគល់ទទួលប្រព័ន្ធ/ប្រព័ន្ធរងនៃខ្សែបន្ទាត់ការងារហេដ្ឋារចនាសម្ព័ន្ធនៅក្នុងដំណាក់កាលអន្តរកាល និង ប្រើប្រាស់ប្រព័ន្ធ។

ខ្សែបន្ទាត់ការងារសម្រាប់ការសាកល្បង÷ របាយការណ៍នៃការសាកល្បង គឺជាការប្រគល់ទទួលទិន្នផលសម្រេចនៃខ្សែបន្ទាត់ការងារនេះ ដែលស្ថិតក្នុងដំណាក់កាលអន្តរកាល ។